**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

**មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍**
**សើស្បែកនិងកាមរោគ**

# របាយការណ៍សកម្មភាពស្តីពីការអប់រំផ្សព្វផ្សាយ និងធ្វើតេស្តឈាមរកមេរោគអេដស៍ថ្ងៃទី ២ ក្នុងព្រឹត្តិការណ៍នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក របស់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

សម្រាប់សកម្មភាពថ្ងៃទី២៖ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០២៣

ដោយទទួលបានការណែនាំ និងចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមសាស្ត្រាចារ្យ ឈាង រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងក្រោមការដឹកនាំដោយផ្ទាល់ដោយ **លោកសាស្ត្រាចារ្យជំនួយ អ៊ុក វិជ្ជា** ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នាថ្ងៃអាទិត្យ ១៤ កើត ខែកក្តិក ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹង ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ត្រូវនឹងថ្ងៃទី២ នៃយុទ្ធនាការក្រុមការងារមជ្ឈមណ្ឌលជាតិ និងអង្គការដៃគូពាក់ព័ន្ធបានបន្តយុទ្ធនាការផ្សព្វផ្សាយអប់រំការយល់ដឹងស្តីពីការបង្ការ មេរោគអេដស៍និងជំងឺអេដស៍ និងចុះចែកស្រោមអនាម័យដោយឥតគិតថ្លៃ ដល់កីឡាករអុំទូក និងដល់សាធារណជនដែលចូលរួមនៅក្នុងឱកាសព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ទៅតាមទីតាំងស្តង់ចំនួន ២កន្លែង ផ្សេងគ្នា ទី(១) នៅទីធ្លាក្រុងរណបជ្រោយចង្វារ OCIC ចាប់ពីថ្ងៃទី ២៥ ដល់ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០២៣ រៀបចំដោយក្រសួងសុខាភិបាល មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគ សហការជាមួយអង្គការដៃគូរួមមាន KHANA, MHC, CWPD & AHF និង ទី(២)នៅរមណីដ្ឋានប្រវត្តិ




សាស្ត្រវត្តភ្នំចាប់ពីថ្ងៃទី២៦ ដល់ថ្ងៃទី២៨ ឆ្នាំ២០២៣ រៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សហការជាមួយក្រសួងសុខាភិបាលមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងអង្គការដៃគូ KHANA, AHF, MHC, CWPD & RHAC ។

ជាផែនការតាមការគ្រោងទុកក្រុមការងារក្រុមការងារមជ្ឈមណ្ឌលជាតិ និងក្រុមអង្គការដៃគូពាក់ព័ន្ធបានត្រៀមទុកនូវកម្លាំងសម្រាប់ចុះអនុវត្តយុទ្ធនាការ សម្ភារ និងខិត្តប័ណ្ណអប់រំផ្សព្វផ្សាយសម្រាប់សកម្មភាពនៃការអប់រំផ្សព្វផ្សាយពីមេរោគអេដស៍ជំងឺអេដស៍ក្នុងព្រឹត្តិការណ៍នេះនូវស្រោមអនាម័យ ចំនួន ១០០,០០០ ស្រោម ទឹករំអិល ចំនួន ៣០,០០០ កញ្ចប់ ខិត្តប័ណ្ណផ្សព្វផ្សាយអំពីការការពារ និងធ្វើតេស្ត ឈាមចំនួន ២០,០០០ សន្លឹក ខិត្តប័ណ្ណស្តីពី PrEP ចំនួន ២០,០០០ សន្លឹក អាវយឺត ចំនួន ១,០០០ អាវ និងខិត្តប័ណ្ណអប់រំផ្សេងៗមួយចំនួនប្រមាណចំនួន២០,០០០ សន្លឹក ទៀត ។

## I. ទីតាំងស្តង់អប់រំផ្សព្វផ្សាយ និងធ្វើតេស្តឈាមរកមេរោគអេដស៍នៅតំបន់ទីក្រុងរណបជ្រោយចង្វារ(OCIC)

➢ **សមាសភាពក្រុមការងារៈ**

- មន្ត្រីមជ្ឈមណ្ឌលជាតិចំនួន ០៨ រូប
- ក្រុមការងារ KHANA ០៤ រូប
- ក្រុមការងារ MHC ១៣ រូប
- ក្រុមការងារ CWPD ០៥ រូប
- ក្រុមការងារ WNU ១០ រូប
- ក្រុមការងារកម្មវិធីអេដស៍មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ ០៣ រូប

➢ **សកម្មភាពៈ**



សម្រាប់ថ្ងៃទី២ នៃយុទ្ធនាការអប់រំផ្សព្វផ្សាយស្តីពីមេរោគអេដស៍ជំងឺអេដស៍ក្នុងព្រឹត្តិការណ៍នៃពិធីបុណ្យអុំទូក បណ្តែត ប្រទីប និងសំពះព្រះខែ អកអំបុកបានបន្តយ៉ាងរលូន ដោយមានការចូលរួមដោយមន្ត្រីជំនាញមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ សហការណ៍អង្គកាដៃគូពាក់ព័ន្ធរួមមាន(KHANA, MHC, CWPD) សរុបចំនួន ២៦រូប នៅទីតាំងទីក្រុងរណបជ្រោយចង្វារ(OCIC) ដែលជាកន្លែងកីឡាករស្នាក់នៅ ដោយបានបែងចែកជាក្រុមចល័តសម្រាប់ចុះផ្សព្វផ្សាយអប់រំដោយផ្ទាល់ដល់កីឡាករអុំទូក និងប្រជាពលរដ្ឋទូទៅស្តីពីការបង្ការការចម្លងមេរោគអេដស៍ ការធ្វើតេស្តរកមេរោគអេដស៍ ការចែកជូនអាវយឺត ចែកទឹករំអិល និងស្រោមអនាម័យតាមទីតាំងនីមួយៗដោយឥតគិតថ្លៃ។ ជាកិច្ចបញ្ចប់ថ្ងៃទី២ ក្រុមការងារបានធ្វើការចែកជូននូវខិត្តប័ណ្ណអប់រំផ្សព្វផ្សាយនានារបស់ក្រុមការងារមជ្ឈមណ្ឌលជាតិ ដៃគូពាក់ព័ន្ធរួមទាំងអាវយឺត ស្រោមអនាម័យ ទឹករំអិល និងបាទទួលធ្វើតេស្តឈាមជូនបងប្អូនកីឡាករបានមួយចំនួនផងដែរ។

## II. ទីតាំងស្តង់អប់រំផ្សព្វផ្សាយ និងធ្វើតេស្តឈាមរកមេរោគអេដស៍នៅរមណីដ្ឋានប្រវត្តិសាស្ត្រវត្តភ្នំ

➢ **សមាសភាពក្រុមការងារៈ**

- មន្ត្រីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

- មន្ត្រីមជ្ឈមណ្ឌលជាតិចំនួន ៣៥ រូប
- ក្រុមការងារ KHANA ០៤ រូប
- ក្រុមការងារ FHI360 (Epic) ០៤ រូប
- ក្រុមការងារ MHC ១៣ រូប
- ក្រុមការងារ CWPD ០៤ រូប
- ក្រុមការងារ AHF ១៥ រូប (OW ១០ រូប)
- ក្រុមការងារ WNU ១០ រូប
- ក្រុមការងារកម្មវិធីអេដស៍មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ ០៣ រូប

➢ **សកម្មភាព៖**

សម្រាប់ថ្ងៃទី២ ទីតាំងរមណីដ្ឋានប្រវត្តិសាស្ត្រវត្តភ្នំទើបនឹងបានចាប់ផ្តើមក្នុងយុទ្ធនាការអប់រំផ្សព្វផ្សាយស្តីពី មេរោគអេដស៍ ជំងឺអេដស៍ក្នុងព្រឹត្តិការណ៍នៃពិធីបុណ្យអុំទូក បណ្តែត ប្រទីប និងសំពះព្រះខែ អកអំបុកនឹងអនុវត្តយ៉ាងរលូនដោយមាន



ការចូលរួមដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មន្ត្រីជំនាញមជ្ឈមណ្ឌល ជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ សហការណ៍អង្គការដៃគូពាក់ព័ន្ធរួមមាន(KHANA, AHF, MHC, CWPD & RHAC) សមាជិកសរុបចំនួនប្រមាណ ៣២ រូប នៅទីតាំងទីរមណីដ្ឋានប្រវត្តិសាស្ត្រវត្តភ្នំដែលជាកន្លែងកីឡាករដើរលេងកំសាន្ត ដោយបានបែងចែកជាក្រុមចល័តសម្រាប់ចុះផ្សព្វផ្សាយអប់រំដោយផ្ទាល់ដល់កីឡាករអុំទូក និងប្រជាពលរដ្ឋទូទៅស្តីពីការបង្ការការចម្លងមេរោគអេដស៍ ការធ្វើតេស្តរកមេរោគអេដស៍ការចែកជូនអាវយឺត ចែកទឹករអិល និងស្រោមអនាម័យតាមទីតាំងនីមួយៗដោយឥតគិតថ្លៃ។ ក្នុងនោះផងដែរក៏មានក្រុមការងារពីសំណាក់វិទ្យុបារាំងអន្តរជាតិ(RFI) បានចុះយកព័ត៌មាន និងនូវយុទ្ធនាការនេះផងដែរដើម្បីចូលរួមចំណែកក្នុងយុទ្ធនាការផ្សព្វផ្សាយអប់រំក្នុងព្រឹត្តិការណ៍ព្រះរាជពិធីបុណ្យអុំទូក បណ្តែត



សកម្មភាពអប់រំផ្សព្វផ្សាយ និងធ្វើតេស្តឈាមរកមេរោគអេដស៍ក្នុងព្រឹត្តិការណ៍នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក

ប្រទីប សំពះព្រះខែ និងអកអំបុក មានរៀបចំជាស្តង់ និងក្រុមចល័តសម្រាប់ផ្សព្វផ្សាយអប់រំដល់កីឡាករអុំទូក ប្រជាពលរដ្ឋទូទៅស្តីពីការបង្ការការចម្លងមេរោគអេដស៍ការធ្វើតេស្តរកមេរោគអេដស៍ការចែកជូនអាវយឺត ចែកទឹករំអិលដោយឥតគិតថ្លៃ។

នាពេលល្ងាចថ្ងៃដដែលក៏មានការរៀបចំការប្រគុំតន្ត្រីផងដែរ ក្រោមការរៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងអង្គការដៃគូដោយមានការចូលរួមក្រោមអធិបតីភាព **ឯកឧត្តមអគ្គលេខាធិការ** អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នូវការសម្តែង Show ដោយក្រុមការងារ និងការអប់រំដើម្បីបញ្ជ្រាបការយល់ដឹងស្តីពីការបង្ការ មេរោគអេដស៍និងជំងឺអេដស៍ និងដាស់តឿនក្រើនរំឭកដល់កីឡាករអុំទូក និងបងប្អូនជនរួមជាតិទាំងអស់ សូមឱ្យប្រុងប្រយ័ត្នបង្ការខ្លួនជាប់ជានិច្ច



កុំឱ្យឆ្លងមេរោគអេដស៍ ព្រោះជំងឺអេដស៍ នឹងសុំឱ្យប្រើប្រាស់ស្រោមអនាម័យឱ្យបាន១០០%នៅពេលមានដៃគូក្រៅ និងប្រញាប់ទៅធ្វើតេស្តឈាមរកមេរោគអេដស៍ប្រសិនបើសង្ស័យថាមានផ្ទុក មេរោគអេដស៍ដើម្បីឆាប់បានទៅទទួលសេវាផ្តល់ប្រឹក្សា និងទទួលឱសថពន្យារជីវិតដោយឥតគិតថ្លៃ។

សមិទ្ធផលសង្ខេបរួមទាំងពីរទីតាំងសម្រាប់ថ្ងៃទី ២៥ ដល់ ២៦ ខែ វិច្ឆិកា ឆ្នាំ ២០២៣

| ល.រ | សកម្មភាពទាំង ២ទីតាំង | ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២៣ | ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០២៣ | ផ្សេងៗ |
|---|---|---|---|---|
| ១ | បានអប់រំផ្សព្វផ្សាយ | ២,៥៤៦ នាក់ | ៥,១១៣ នាក់ | |
| ២ | បានធ្វើតេស្តឈាម | ១៣ នាក់ | ៤៣ នាក់ | |
| ៣ | លទ្ធផលអេដស៍តេស្តប្រតិកម្ម | ០ នាក់ | **២ នាក់** | |
| ៤ | លទ្ធផលស្វាយតេស្តប្រតិកម្ម | ០ នាក់ | **២ នាក់** | |
| ៥ | បានចែកស្រោមអនាម័យ | ១២,៩៨៤ ស្រោម | ២៩,៤៨៧ ស្រោម | |
| ៦ | បានចែកទឹករំអិល | ៤,៥៥៨ កញ្ចប់ | ៧,០៣៤ កញ្ចប់ | |
| ៧ | បានចែកខិត្តប័ណ្ណ | ២,៦៨៧ សន្លឹក | ៥,២៦៩ សន្លឹក | |
| ៨ | បានចុះឈ្មោះសេវា PrEP | ០ នាក់ | ១ នាក់ | |
| ៩ | អាវយឺតសម្រាប់អប់រំ | ២៥០ អាវ | ៤០០ អាវ | |

ថ្ងៃអាទិត្យ ១៤កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០២៣

| បានឃើញ និងឯកភាព | បានពិនិត្យត្រឹមត្រូវ | ធ្វើសេចក្តីរាយការណ៍ដោយ |
|---|---|---|
| សាស្ត្រាចារ្យ ជ.អ៊ឹក វិជ្ជា | វេជ្ជបណ្ឌិត ង៉ូវ ប៊ូរ៉ា | លោក ចំរើន ប៊ូរ៉ា |